ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

&&&@&&&

ក្រសួង អប់រំ យុវជន និង កីឡា

លេខ : ៤៥៣ អយក. ប្រក

# ប្រកាស

## ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ សំបួរមាស មកជាសាលាបឋមសិក្សាពេញលក្ខណៈ

## រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស .រកត -១១៩៨- ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស - ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស -រកម -០១៩៦- ០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពី ការរៀបចំនិងការប្រព្រឹត្តរបស់ក្រសួង អប់រំ យុវជន និង កីឡា

-បានពិនិត្យលិខិតលេខ១២អយក.ខដចុះថ្ងៃទី១៣ខែកុម្ភៈឆ្នាំ២០០២របស់ការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌដង្កោរាជធានីភ្នំពេញ

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និងមត្តេយ្យសិក្សា

## សម្រេច

ប្រការ ១ : -ផ្តាច់សាលាឧបសម្ព័ន្ធសំបួរមាស ចេញពីសាលាបឋមសិក្សា ដង្កោ ដែលមានទីតាំងស្ថិតនៅភូមិគោកមាស សង្កាត់ ភ្លើង ឆេះរទេះ ខណ្ឌដង្កោ រាជធានីភ្នំពេញ មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពី ឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

ប្រការ ២ : -សាលាបឋមសិក្សាសំបួរមាស ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋាន ប្រើប្រាស់ក្របខណ្ឌសំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍ កំនត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និងមត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌ ដង្កោ នាយកសាលាបឋមសិក្សា សំបូរមាស នាយកសាលាបឋមសិក្សា ដង្កោមានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ

-ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាបជាពិមាន "

-សាលា ក្រុង ភ្នំពេញ " ជូនជ្រាបជាពតិមាន "

-ដូចប្រការ ៥

-កាលប្បវត្តិ -ឯកសារ នា-បម

ភ្នំពេញ ,ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០២

ជ-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

**អ៊ឹម_សិទ្ធី**